**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ព្រែកគ្រៀង សម្រាប់រយៈពេល ៣ ឆ្នាំ

## (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ព្រែកគ្រៀង |
| ភូមិ | ៖ | ព្រែកគ្រៀង |
| ឃុំ | ៖ | វឌ្ឍនៈ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

**ខែមករា ឆ្នាំ២០១៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ព្រែកគ្រៀង
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ព្រែកគ្រៀង |
| ភូមិ | ៖ | ព្រែកគ្រៀង |
| ឃុំ | ៖ | វឌ្ឍនៈ |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ........................................................................................................ ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........................................................................ ២
ក. ប្រជាពលរដ្ឋ ............................................................................................................ ២
ខ. មុខរបរ .................................................................................................................... ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ................................ ២
ក. ទីតាំង ..................................................................................................................... ២
ខ. ដែននេសាទ ............................................................................................................. ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស .......................................................... ៣
ឃ. ធនធានជលផល ...................................................................................................... ៣
៤. ការធ្វើនេសាទ ........................................................................................................ ៤
ក. អ្នកនេសាទ ............................................................................................................. ៤
ខ. ឧបករណ៍នេសាទ ...................................................................................................... ៤
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ .............................................................. ៥
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ................................................................... ៥
ក. ទស្សនៈវិស័យ .......................................................................................................... ៥
ខ. គោលបំណងរួម ........................................................................................................ ៥
គ. គោលបំណងជាក់លាក់ ............................................................................................... ៥
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ................................................... ៦
ឃ.១. ធនធានជលផល និងអេកូឡូស៊ី .............................................................................. ៦
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ................................................................................... ៨
ឃ.៣. ការគ្រប់គ្រង ....................................................................................................... ១០
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ....................................................................... ១៤
ច. យុទ្ធសាស្ត្រ ............................................................................................................. ១៤
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិខ្សាច់លាវរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) .......... ១៦
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ............................................ ២៥

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទព្រែកគ្រៀង មានទីតាំងស្ថិតនៅភូមិព្រែកគ្រៀង ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ។ សហគមន៍នេសាទនេះ បានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផលក្រចេះ និងគណៈកម្មការសហគមន៍នេសាទនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១។ សហគមន៍នេសាទព្រែកគ្រៀង ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលក្រចេះ។ យោងតាមភាពចាំបាច់របស់សហគមន៍នេសាទ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សមាសភាគទី១ ដែលអនុវត្តដោយនាយខណ្ឌរដ្ឋបាលក្រចេះ បានសម្របសម្រួលចុះធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨។ ឆ្លងតាមការធ្វើបច្ចុប្បន្នភាព សមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការសរុបចំនួន៨៩នាក់ ស្រី៤២នាក់ ក្នុងនោះមាន៨៥គ្រួសារ។ គណៈកម្មការសហគមន៍នេសាទមានចំនួន ៩នាក់ និងបានជ្រើសរើសជំនួយការជាស្ត្រីចំនួន ២នាក់ ដោយបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងការឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនេះ ជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម ៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានមានការបាត់បង់ពូជត្រីធំៗ បាត់បង់ព្រៃលិចទឹកដោយសារការកាប់រាន ទឹកមានស្លែច្រើន បរិមាណផលត្រីថយចុះ បាត់បង់ទីជម្រកត្រីសម្រាប់ពងកូន អន្លង់រាក់ និងមានការបាក់ច្រាំងទន្លេ
- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានតម្លៃកសិផល និងបន្លែទាប ស្ពានរងការខូចខាត ខ្វះចំណេះដឹងលើផ្នែកកសិកម្ម ខ្វះការបណ្តុះបណ្តាលជំនាញមុខរបរចិញ្ចឹមជីវិត ខ្វះដើមទុនប្រកបរបរ ប្រជាពលរដ្ឋមានប្រាក់ចំណូលទាប និងទីផ្សារនៅឆ្ងាយពីភូមិ
- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទមានកាន់តែច្រើនដូចជាឆក់ បំពុល ស្បៃមុងនិងវាយមងជាក្រុម សហគមន៍នេសាទខ្វះទូក ប្រេង សម្ភារ និងថវិកាសម្រាប់ល្បាត ខ្វះសម្ភាររដ្ឋបាល ជនល្មើសមិនខ្លាចសហគមន៍នេសាទ កិច្ចសហការពីប៉ូលីសប៉ុស្តិ៍រដ្ឋបាល និងស្ថាប័នពាក់ព័ន្ធមិនទាន់រលូន មិនទាន់មានស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ ការយល់ដឹងរបស់គណកម្មការសហគមន៍នេសាទពីច្បាប់ជលផលនៅមានកម្រិត ខ្វះការលើកទឹកចិត្តដល់គណៈកម្មការសហគមន៍នេសាទ ការយល់ដឹងពីបរិស្ថាន និងសារៈសំខាន់នៃធនធានជលផលដែលជាផលប្រ យោជន៍រួមនៅមានកម្រិត គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ សហគមន៍នេសាទនៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ម្យ៉ាងទៀតសមាជិកសហគមន៍នេសាទពួកគាត់គិតថាការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទជាការងាររបស់គណៈកម្មការ។ ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរ ព្រមទាំងការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍មាន១.៤៥១នាក់ ប្រុសចំនួន៧៤៥នាក់ ស្រី៧០៦នាក់ ក្នុងនោះមាន ៣២៩គ្រួសារ ក្នុងនោះមានជនជាតិខ្មែរទាំងអស់។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ស្ថានភាពប្រជាពលរដ្ឋក្នុងភូមិព្រែកគ្រៀង មានដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ២០ នាក់
- ចំនួនបុរសពោះម៉ាយមាន ២០ នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃមាន ២ នាក់ ស្រី ១ នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន ៥ នាក់ (ស្រី២នាក់) ថ្នាក់បឋមសិក្សាចំនួនសរុប ២៥៣នាក់ (ស្រី ១២៥នាក់) និង កម្រិតមធ្យមសិក្សា៤៥នាក់ (ស្រី ២៥នាក់)។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើស្រែចំនួនប្រុស ៣៣៦នាក់ ស្រី ៣៣១នាក់ ដែលមានទំហំដីសរុបចំនួន ១២០ហិចតា
- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ប្រុស ៥៥នាក់ ស្រី ៥៤នាក់
- ធ្វើចំការ (បន្លែ និង ឈើហូបផ្លែ) ចំនួនប្រុស ១៨នាក់ ស្រី ២៥នាក់ ទំហំដីចំការ៤៥ហិចតា
- ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក គោ ក្របី) ប្រុស១៣១នាក់ ស្រី ១៣៨នាក់
- លក់ដូរជាអាជីព ប្រុស១៣នាក់ ស្រី ២២នាក់
- ជាងផ្ទះចំនួន ១១នាក់
- ជាងកាត់សក់ អ៊ុតសក់ កាត់ដេរ ០៥នាក់។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ព្រែកគ្រៀងជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ព្រែកគ្រៀង ស្ថិតនៅតាមដងទន្លេមេគង្គ មានទំហំ ១.០៤០ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងកើតទល់នឹងពាក់កណ្តាលទន្លេមេគង្គព្រំប្រទល់ឃុំវឌ្ឍនៈ ស្រុកសំបូរ និងឃុំសំបុក ស្រុកចិត្របុរី
- ខាងលិចទល់នឹងមាត់ព្រែកអូរគ្រៀងផ្នែកខាងលិច ភូមិជ្រោយបន្ទាយ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ
- ខាងត្បូងទល់នឹងភូមិជ្រោយបន្ទាយ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ខាងជើងទល់នឹងភូមិអន្លង់ព្រះគោ ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ព្រែកគ្រៀង ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងតាមកោះ។ កន្លែងនេសាទសហគមន៍ព្រែកគ្រៀង មានបឹងចំនួន៣ ព្រែកចំនួន៣ និងអន្លង់ចំនួន៥ គឺ៖

- បឹងចារ ទំហំ ១,២៥ ហិកតា មានទឹកពីខែមិថុនា ដល់ កុម្ភៈ
- បឹងត្រស់ ទំហំ ១,៥០ ហិកតា មានទឹកពីខែមករា ដល់ ធ្នូ
- បឹងតាតូវ ទំហំ ០,៦០ ហិកតា មានទឹកពីខែមិថុនា ដល់ កុម្ភៈ
- ព្រែកគ្រៀង ប្រវែង ៥០០០ម មានទឹកពីខែមករា ដល់ ធ្នូ
- ព្រែកល្វា ប្រវែង ៥០០ម មានទឹកពីខែសីហា ដល់ មករា
- ព្រែកចាម ប្រវែង ២០០ម មានទឹកពីខែសីហា ដល់ មករា
- អន្លង់កោះខ្លែង ទំហំ ០,៦ ហិកតា មានទឹកពេញមួយឆ្នាំ
- អន្លង់វែង ទំហំ ០,៦ ហិកតា មានទឹកពេញមួយឆ្នាំ
- អន្លង់វិល ទំហំ ០,៦ ហិកតា មានទឹកពេញមួយឆ្នាំ
- អន្លង់កោះទ្រនំក្អែក ទំហំ ០,៨១ ហិកតា មានទឹកពេញមួយឆ្នាំ
- អន្លង់កោះក្របី ទំហំ ០,៤៥ ហិកតា មានទឹកពេញមួយឆ្នាំ។

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- - អន្លង់កោះខ្លែង ទំហំ ០,៦ ហិកតា (បណ្តោយ ១០០ម និងទទឹង ៦០ម)
- - អន្លង់វែង ទំហំ ០,៦ ហិកតា (បណ្តោយ១៥០ និង ទទឹង ៤០ម)
- - អន្លង់វិល ទំហំ ០,៦ ហិកតា (បណ្តោយ ២០០ម និងទទឹង ៣០ម)
- - អន្លង់កោះទ្រនំក្អែក ទំហំ ០,៨១ ហិកតា (បណ្តោយ ១៣០ម និងទទឹង ៧០ម) និង
- - អន្លង់កោះក្របី ទំហំ ០,៤៥ ហិកតា (បណ្តោយ ១០០ម និង ទទឹង ៤៥ម)

ជាតំបន់ដែលមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី៖

ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ាមុខ១ ត្រីប៉ាវ៉ាមុខ២ ត្រីប៉ាកក ត្រីគ្រំ ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីក្របី ត្រីប្រម៉ា ត្រីត្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ញឹង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លួញ ត្រីចេកទុំ និងត្រីអន្ទង់។

ឃ.២. ប្រភេទវារីសត្វ ៖

ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ អន្ទង់ ពស់ កំពិស កង្កែប ហ៊ីង និងគីង្គក់។

ឃ.៣. ប្រភេទសត្វស្លាប ៖

ក្អែកទឹក កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ ទាទឹក និងក្អែកគោក។

ឃ.៤. ព្រៃលិចទឹក និងរាវិរុក្ខជាតិ ៖

ដើមរៃ ដើមអណ្ដែង ដើមជ្រៃ ដើមត្រែង ដើមល្វាទឹក រាំងទឹក ដើមក្តុល ព្រីងទឹក ដើមអ៊ុយយ៉ាស់។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨៩ នាក់ ស្រី ៤២ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ១០៩ នាក់ ស្រី ៥៤ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ ១១៥ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| សំណាញ់ | វង់ | ៧០ | ៦០ | ២០ | ក្រឡា១,៥-១៥សម ប្រវែង ៤,៥-៧ម | ក្រឡា១,៥-១៥សម ប្រវែង ៤,៥-៧ម | ក្រឡា១,៥-១៥សម ប្រវែង៤,៥-៧ម | មករា ដល់ ធ្នូ |
| មង | ត្បូង (១ត្បូង៨០ម) | ១៥ | ៥៥ | ៧០ | ២.៥- ៦ស.ម | ៦-១៥ ស.ម | ៩-១៥សម | មករា ដល់ ធ្នូ |
| សន្ទូច រនង | សាង (១សាង ១០០ផ្លែ) | ៦០ | ៨០ | ១០០ | ផ្លែលេខ ៧-១៥ | ផ្លែលេខ ៧-១៥ | ផ្លែលេខ៩-១២ | តុលា ដល់ សីហា |
| បង្កៃ | ផ្លែ | ៦០០ | ៦០០ | ៥០០ | ផ្លែលេខ៥ | ផ្លែលេខ៥ | ផ្លែលេខ៥ | មីនាដល់ វិច្ឆិកា |
| បង្កង | ផ្លែ | ៧០០ | ៧០០ | ៦.០០០ | ផ្លែលេខ១០-១៥ | ផ្លែលេខ១០-១៥ | ផ្លែលេខ១០ | តុលាដល់កុម្ភៈ |
| លប | គ្រឿង | ៤៥០ | ៤៥០ | | មុខកាត់១,២ម បណ្តោយ១,៩ម | មុខកាត់១,២ម បណ្តោយ១,៩ម | | ឧសភា ដល់ តុលា |
| ទ្រូ | គ្រឿង | ៣ | ២ | | មុខកាត់ ០,៣ម បណ្តោយ១,២ម | មុខកាត់០,៣ម បណ្តោយ១,២ម | | ឧសភា ដល់ តុលា |
| ឈ្នាង ជញ្ជាត់ | គ្រឿង | ៣ | ២ | | មាត់០.៦ម បណ្តោយ ០,៨៥ម | មាត់០.៦ម បណ្តោយ ០,៨៥ម | | សីហា ដល់ តុលា |
| អង្រុត | គ្រឿង | ៥ | ៧ | | មាត់០,៤ម កំពស់០,៦ម | មាត់០,៤ម កំពស់០,៦ម | | វិច្ឆិកា ដល់ មករា |

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអុំ/ចែវ | ០២ | ០២ | | | ៣០០គ.ក | ៣០០គ.ក | | | |
| ទូកមានម៉ាស៊ីន | ៦០ | ៧៧ | ២០ | ២០០-៥០០គ.ក | ២០០-៥០០គ.ក | ២០០-៣០០គ.ក | ៥,៥-១៨សេះ | ៥,៥-១៨សេះ | ១៣-២៧សេះ |

គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទព្រែកត្រៀង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ.គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទមានគោលបំណងរួមដូចខាងក្រោម ៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ ទេសចរណ៍ធម្មជាតិ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ទីតាំង | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា ដល់ ធ្នូ | សំណាញ់ | ក្រឡា១,៥-១៥សម ប្រវែង៤,៥-៧ម | ១៥០ វង់ | ៩០ (៣០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ |
| | មករា ដល់ ធ្នូ | មង | ២.៥-៤ស.ម ប្រវែង៨០/ត្បូង | ១៤០ ត្បូង | |
| | តុលា ដល់ សីហា | សន្ទូចរនង | ផ្លែលេខ៧-១៥ និង ១០០ ផ្លែ/សាង | ២៤០ សាង | |
| | មីនា ដល់ វិច្ឆិកា | បង្កៃ | ផ្លែលេខ ៥ | ១៧០០ ផ្លែ | |
| | តុលា ដល់ កុម្ភៈ | បង្កង | ផ្លែលេខ ១០-១៥ | ៧២០០ ផ្លែ | |
| | ឧសភា ដល់ តុលា | លប | មុខកាត់១,២មបណ្ដោយ១,៩ម | ៩០០ គ្រឿង | |
| | ឧសភា ដល់ តុលា | ទ្រូ | មុខកាត់០,៣ម បណ្ដោយ១,២ម | ៥ គ្រឿង | |
| | សីហា ដល់ តុលា | ឈ្នងជញ្ជាត់ | មាត់០.៦ម បណ្ដោយ០,៨៥ម | ៥ គ្រឿង | |
| | វិច្ឆិកា ដល់ មករា | អង្រុត | មាត់០,៤ម កំពស់០,៦ម | ១២ គ្រឿង | |

ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូខខាងក្រោមៈ

| ឈ្មោះ / ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់កោះខ្លែង | ០,៦ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | កំណត់ព្រំប្រទល់កន្លែងអភិរក្ស | ១.០០០ (៥x២០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់វែង | ០,៦ | | បោះបង្គោល | ២២០ (១១x២០) | | |
| អន្លង់វិល | ០,៦ | | ដាក់ស្លាកសញ្ញាហាមឃាត់ | ២០០ (៤x៥០) | | |
| អន្លង់កោះ | ០,៩១ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ទ្រនំក្អែក | | | ផលិតនិងផ្សព្វផ្សាយផែនទីអន្លង់អភិរក្ស | ១០០ | | |
| អន្លង់កោះក្របី | ០,៤៥ | | សង់រោងយាម | ១.០០០ | | |
| | | | • ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស<br>• សង់រោងយាម<br>• រៀបចំក្រុមល្បាត<br>• ចុះល្បាតជាប្រចាំ | | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ព្រំប្រទល់ភូមិព្រែកគ្រៀងអន្លង់ព្រះគោ មាត់ព្រែកគ្រៀង មុខវត្តព្រែកគ្រៀង ក្បាលបឹងគ្រស់ ផ្លូវវាលធំ និង ចំការតាម៉ាត់ | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ (លើគោក) | ៦ បង្គោល | ១.៨០០ (៦x៣០០) | តុលា ២០១៩ | ធ្នូ ២០១៩ |
| កោះតានីន កោះតាប៉ាវ កោះពោរ កោះខ្លែង និងមាត់ព្រែកគ្រៀង | ពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ (ក្នុងទឹក) | ៥ ពោង | ២.៥០០ (៥x៥០០) | តុលា ២០១៩ | ធ្នូ ២០១៩ |
| មុខវត្តព្រែកគ្រៀង | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ១ ផ្ទាំង | ៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅតាមច្រាំងទន្លេ មាត់អូរព្រែក និងតាមកោះ | ១០-៣០ម តាមមាត់អូរព្រែក ទន្លេ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន សណ្ដាន់ រាំង ឆ្អឹងត្រី និងប្រភេទព្រៃចម្រុះ | ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក | ១០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | | | ដាំព្រៃលិចទឹកចំនួន ១.៥០០ ដើម | ៤០០ | | |
| | | | ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់ចំនួន ១៥ | ៣០០ (១៥x២០) | | |
| | | | ចុះល្បាតជាប្រចាំ | | | |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខសកម្មភាព | សកម្មភាព | ប្រភេទ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមគោ<br>• ចែកពូជគោ<br>• តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ២០គ្រួសារ (២០គ្រួសារx៣០០ | ៦.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសអ្នកទទួលផល<br>• បណ្ដុះបណ្ដាលពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ<br>• ផ្ដល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ០៧ គ្រួសារ (៧គ្រួសារx៣០០) | ២.១០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

| ប្រភេទមុខសកម្មភាព | សកម្មភាព | ប្រភេទ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួនបន្លែជាគ្រួសារ<br>• ចែកគ្រាប់ពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | បន្លែគ្រប់មុខ | ៣២ គ្រួសារ (៣២គ្រួសារx៣០០) | ៩.៦០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត<br>• ចែកពូជ អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតចំបើង | ០៥ គ្រួសារ (៥គ្រួសារx៣០០) | ១.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

**ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (ត្រីឆ្ពិន និងត្រីអណ្តែង) | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី.ជាលក្ខណៈគ្រួសារ<br>• ធ្វើអាងចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | អាងស៊ីម៉ងត៍ ទំហំ ៤ម x ៣ម | ១៥ គ្រួសារ (១៥គ្រួសារ x៥០០) | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវក្រាលដីគ្រួសធម្មជាតិក្រោយភូមិ (៣.៦០០ម) | ១ ខ្សែ | ៣៦.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សង់ផែសម្រាប់អ្នកទេសចរមកមើលផ្សោត | ៣ ផែ (៣ផែx៣.៣០០) | ៩.៩០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់លូកាត់ផ្លូវ | ១០ កន្លែង (១០កន្លែងx១.៥០០) | ១៥.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់ទ្វារទឹក | ២ កន្លែង (២កន្លែងx៣.៥០០) | ៧.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

## ឃ.៣. ការគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៧ដង/១ខែ (៧ដងx១២ខែx៣x២៥) | ៦.៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ (២ដងx១២ខែx៣x២៥) | ១.៨០០ | | |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១២ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ២ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក ៤ម | ១ | | | |

| | | | | | |
|---|---|---|---|---|---|
| | គុណ៦ម | | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរប្រវាក់ចាក់ទូក | ២ឈុត | | | |
| | អាវយឺត | ២៤អាវ | | | |
| ទិញទូកស្នាច់ និងម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | កក្កដា ២០១៩ | ២០២០ |
| ប្រេងសម្រាប់ល្បាត | | ៨០ លីត្រ/ខែ (៨០លីត្រx៣៦ខែx១) | ២.៨៨០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ (៦ដងx១០០) | ៦០០ (៣ឆ្នាំ) | | |
| សាងសង់ទីស្នាក់ការសហគមន៍ | | ១ កន្លែង | ៣.០០០ | | |

ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/ខែ (៣៦ដងx១០) | ៣៦០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ (តំណាងសហគមន៍នេសាទ) | ១ដង/ខែ (៣៦ដងx១០) | ៣៦០ | | |
| ចូលរួមប្រជុំបណ្ដាញសហគមន៍នេសាទ | តាមការអញ្ជើញ | ៥០ | | |
| យុទ្ធនាការហែរក្បួនបំផុសការយល់ដឹងអំពីច្បាប់ជលផល និងសារៈប្រយោជន៍នៃធនធានជលផល (សមាជិកទាំងអស់) | ១ដង/១ឆ្នាំ (៣ដងX១០០) | ៣០០ | | |
| បណ្ដុះបណ្ដាលគណកម្មការសហគមន៍នេសាទអំពីច្បាប់ជលផល | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្ដុះបណ្ដាលរបៀបធ្វើកំណត់ហេតុ និងរបាយ | | ៦០ | | |

| | | | | |
|---|---|---|---|---|
| ការណ៍ | | | | |
| បណ្តុះបណ្តាលជំនាញរៀបចំផែនការគ្រប់គ្រង | | ៦០ | | |
| បណ្តុះបណ្តាលជំនាញសម្របសម្រួល | | ៦០ | | |
| បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ (៣ឆ្នាំ) | ៦០ | | |
| បណ្តុះបណ្តាលរបៀបគ្រប់គ្រងបញ្ជីចំណូលចំណាយ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៦០ | | |
| ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ១.០០០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទ | | ៧៥ | | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | | ៧៥ | | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្ស | | ៧៥ | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាពនិងភាគទានប្រចាំឆ្នាំ | ១ដង/ឆ្នាំ (៣ដងx១០) | ៣០ | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ (៣ដងx១០០) | ៣០០ | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះសមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ១១,១៣ | ៥០០ រៀល/នាក់ (៨៩នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | កក្កដា ២០១៩ | មិថុនា ២០២២ | ៣៣៣,៧៥ | ៥.០០០ រៀល/គ្រួសារ ក្នុងមួយឆ្នាំ (៨៩នាក់) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | ១២៥.៥១៥,១ | សរសេរគម្រោងចំណាយថវិកា ៥០០ដុល្លារ |
| សរុប | | | | ១២៥.៨០០ | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការសហគមន៍នេសាទ | ១២០ (១២ដងx១០) |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ | ៦០០ (៣ដងx២០០) |

### ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឲ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ

- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- អញ្ជើញស្ត្រីចូលរួមកិច្ចប្រជុំ និងសកម្មភាពនានា របស់សហគមន៍នេសាទ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទ ចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០% ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- ជ្រើសរើសស្ត្រី៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព ក្នុងនោះស្ត្រីជាមេគ្រួសារ ៧%
- ផ្តល់ឱកាសដល់ស្ត្រីសមាជិកសហគមន៍នេសាទនៃអ្នកទទួលផលសរុបទទួលបានផលប្រយោជន៍ពីគម្រោង
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រី ជាគណៈកម្មការមិនបោះបង់ការងារសហគមន៍នេសាទ
- រៀបចំការប្រជុំឱ្យស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណៈកម្មការសហគមន៍នេសាទ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកគ្រៀង រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រ ភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបយករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៩០ (៣០/១ឆ្នាំ) | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | កំណត់ព្រំប្រទល់កន្លែងអភិរក្ស | កន្លែងអភិរក្សមានព្រំប្រទល់ច្បាស់លាស់ដោយមានការទទួលស្គាល់ពីស្ថាប័នជំនាញ និងមានផែនទីសម្គាល់អន្លង់អភិរក្ស | ១.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ | ស្លាកសញ្ញាសម្គាល់កន្លែងអភិរក្សចំនួន ១១ ត្រូវបានដាក់សម្គាល់ | ២២០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផលិត និងផ្សព្វផ្សាយផែនទីកន្លែងអភិរក្ស | ផែនទីចំនួន ៤ ផ្ទាំងត្រូវបានដាក់នៅកន្លែងអភិរក្ស | ២០០ | | | | |
| | ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស | សមាជិកសហគមន៍នេសាទ ៣៥នាក់ស្រី១០នាក់ចូលរួម និងយល់ដឹងពីកន្លែងអភិរក្ស | ១០០ | | | | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សង់រោងយាម | រោងយាមចំនួន០១ ទំហំ៤ម x៥ម ត្រូវបានសាងសង់ | ១.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
